**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ : ១២៧៧ ស.ហ.វ. - ប.ទ.

# សារាចរអន្តរក្រសួង
# ស្តីពី
# វិធានការទប់ស្កាត់ភាពពុំស្មោះត្រង់នៃ
# ការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍

*អនុវត្តតាមគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាល រហូតមកដល់ពេលនេះ វិស័យទូរគមនាគមន៍មានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងផ្នែកបរិមាណនិងគុណភាព ព្រមទាំងបានរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។*

*គោលបំណងនៃការអនុវត្តនយោបាយបើកទូលាយសម្រាប់វិស័យទូរគមនាគមន៍គឺទាក់ទាញការវិនិយោគ និង បង្កើនចំណូលថវិការដ្ឋ ដោយត្រូវធានាឱ្យបាននូវគោលដៅជាមូលដ្ឋានសំខាន់ៗ ៤ យ៉ាង រួមមាន ៖*

*ទី ១ ) ការប្រកួតប្រជែងដោយស្មើភាពគ្នា,*

*ទី ២ ) ផ្តល់សេវាល្អ និង គុណភាពខ្ពស់,*

*ទី ៣ ) ថ្លៃថោកសមរម្យ,*

*ទី ៤ ) បង្កើនចំណូលថវិកាជាតិ។*

*តាមរយៈការអនុវត្តជាក់ស្តែងនៅបណ្តាឆ្នាំចុងក្រោយនេះ លទ្ធផលផ្លែផ្កាគួរកត់សម្គាល់គឺមានក្រុមហ៊ុនឯកជនជាច្រើនចូលមកវិនិយោគលើវិស័យទូរគមនាគមន៍នៅកម្ពុជា។ ស្របពេលគ្នានឹងកំណើននៃការវិនិយោគរបស់ផ្នែកឯកជន ទីផ្សារទូរគមនាគមន៍នៅកម្ពុជាបានបោះជំហានចូលទៅក្នុងការប្រកួតប្រជែងគ្នាយ៉ាងស្វិតស្វាញរវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់។*

នាពេលថ្មីៗកន្លងមកនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សង្កេតឃើញថា ប្រតិបត្តិករទូរគមនាគមន៍មួយចំនួនបានខិតខំទាក់ទាញអតិថិជនរៀងៗខ្លួនដោយប្រើប្រាស់រូបភាពឃោសនាផ្សព្វផ្សាយផ្សេងៗដូចជា ពុំគិតថ្លៃសន្ទនាក្នុងប្រព័ន្ធតែមួយ, គិតថ្លៃហៅឆ្លងប្រព័ន្ធទាបជាងការកំណត់របស់រដ្ឋ, ការបន្ថែមពេលម៉ោងសន្ទនាដោយពុំគិតថ្លៃៗលៗ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍វាយតម្លៃថា ការឃោសនាផ្សព្វផ្សាយ និង អនុវត្តបែបនេះ គឺជារូបភាពនៃការប្រកួតប្រជែងដោយពុំមានភាពស្មោះត្រង់ក្នុងរបរអាជីវកម្មឡើយ។ លទ្ធផលអវិជ្ជមានដែលនឹងកើតឡើងចំពោះមុខ គឺភាពរអាក់រអួលផ្នែកបច្ចេកទេសរវាងបណ្តាប្រតិបត្តិករទូរគមនាគមន៍ ដែលពុំត្រឹមតែបង្ខូចផលប្រយោជន៍នៃអ្នកប្រើប្រាស់ប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់យ៉ាងធ្ងន់ចំពោះចំណូលថវិការដ្ឋទៀតផង។ ផលវិបាកចុងក្រោយ គឺវិស័យទូរគមនាគមន៍នៅកម្ពុជានឹងជួបវិបត្តិដួលរលំទាំងអស់គ្នាពុំខាន។

ក្នុងមូលហេតុដូចខាងលើ ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលានូវវិបត្តិទូរគមនាគមន៍នៅកម្ពុជា និងបញ្ចៀសការប៉ះពាល់ចំណូលថវិការដ្ឋជាយថាហេតុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមស្នើប្រតិបត្តិករទូរគមនាគមន៍ទាំងអស់អនុវត្តដូចតទៅ៖

១ ) បញ្ឈប់ជាបន្ទាន់នូវរាល់ការឃោសនាផ្សព្វផ្សាយ, ការបង្កើតកម្មវិធីនិងយុទ្ធសាស្ត្រប្រជែងគ្នាដណ្តើមទីផ្សារ, ការរាំងខ្ទប់ការភ្ជាប់បណ្តាញគ្នាទៅវិញទៅមក ដែលជាហេតុនាំបណ្តាលឱ្យជួបវិបត្តិទូរគមនាគមន៍នៅកម្ពុជា ជាពិសេសធ្វើឱ្យប៉ះពាល់ចំណូលថវិកាជាតិដែលបានគ្រោងទុកឱ្យមានកំណើនរៀងរាល់ឆ្នាំនៅក្នុងច្បាប់ហិរញ្ញវត្ថុ។

២ ) រាល់ការឃោសនាផ្សព្វផ្សាយ ត្រូវធ្វើឡើងដោយស្មើភាពគ្នាក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ, ច្បាប់ស្តីពីពន្ធដារ និង លិខិតបទដ្ឋាននានាដែលនៅជាធរមាន។

ឆ្លៀតឱកាសនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមបញ្ជាក់ថា យោងតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ, ច្បាប់ស្តីពីពន្ធដារ និង លិខិតបទដ្ឋានគតិយុត្តិដែលនៅជាធរមាន ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់មានកាតព្វកិច្ចបង់ពន្ធដារនិងចំណូលគ្រប់ប្រភេទជូនរដ្ឋដោយពុំមានការលើកលែងជាដាច់ខាត ទោះបីការផ្តល់សេវាប្រភេទណា ( ទាំងគិតថ្លៃនិងពុំគិតថ្លៃ ) ជូនអតិថិជនក៏ដោយ ។ ក្នុងន័យនេះ ការផ្តល់ជូនអតិថិជននូវការសន្ទនាក្នុងប្រព័ន្ធតែមួយដោយឥតគិតថ្លៃ, ការគិតថ្លៃហៅឆ្លងប្រព័ន្ធទាបជាងការកំណត់របស់រដ្ឋ, ការបន្ថែម

ពេលម៉ោងសន្ទនាដោយពុំគិតថ្លៃៗលៗ របស់ប្រតិបត្តិករទូរគមនាគមន៍មួយចំនួន នឹងពុំអាចគេចផុតពីកាតព្វកិច្ចបង់ពន្ធដារនិងចំណូលផ្សេងៗទៀតនាដំណាច់ការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនីមួយៗបានឡើយ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងចាត់វិធានការដាក់ស្តែងតាមផ្លូវច្បាប់ចំពោះប្រតិបត្តិករទូរគមនាគមន៍ណាដែលបានអនុវត្តផ្ទុយទៅនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ, ច្បាប់ស្តីពីពន្ធដារនិងលិខិតបទដ្ឋានគតិយុត្តិនៅជាធរមាននៅរៀងរាល់ដំណាច់ការិយបរិច្ឆេទនៃឆ្នាំសារពើពន្ធនីមួយៗ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សង្ឃឹមថាប្រតិបត្តិករទូរគមនាគមន៍ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ពិតជាយល់ច្បាស់ និង ទទួលអនុវត្តតាមខ្លឹមសារនៃសារាចរនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**សូរ-ឃុន**

**ចម្លងជូន** :
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ប្រតិបត្តិករទូរគមនាគមន៍
- ឯកសារ កាលប្បវត្តិ



៧